# ព្រះវិហារវត្តភ្នំធនមន្តនិងគំនូររឿងនាងពិម្ពា

ព្រះវិហារវត្តភ្នំធនមន្ត គឺជាស្ថាបត្យកម្មសម័យសង្គមរាស្រ្តនិយមដែលកសាងអំពីឥដ្ឋនិងកំបោរបាយអ សង់នៅលើកូនភ្នំតូចមួយ ស្ថិតនៅក្នុងឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល (រូបលេខ១)។ បើយោងតាមឯកសារបានឱ្យដឹងថា វត្តភ្នំធនមន្ត ឬវត្តធនមន្ត មានឈ្មោះផ្សេងទៀតដូចជា វត្តស្រះស្រង់ ឬវត្តគិរីសោភ័ណ ឬហៅរួមពាក្យទាំងអស់ថា "វត្តស្រះស្រង់គិរីសោភ័ណភ្នំធនមន្ត"។ នៅលើជញ្ជាំងនិងពិតានព្រះវិហារ មានគំនូរយ៉ាងល្អវិសេសនិយាយពីជាតិកំណើតផ្សេងៗរបស់នាងពិម្ពា ដែលតែងអន្ទោលតាមចាប់ជាតិជាកន្សែស្រាវពេជ្ជ។[១] អ្នកស្រាវជ្រាវយល់ថា គំនូរទាំងនោះគូរដំណាលគ្នាតាំងពីកសាងព្រះវិហារ ហើយជាគំនូរសាច់រឿងដែលសង្កេតឃើញលើកយកមកគូរតែនៅព្រះវិហារវត្តភ្នំធនមន្តមួយគត់។[២]



រូបលេខ១ ព្រះវិហារវត្តភ្នំធនមន្ត (រូបមើលពីមុខទិសឦសាន)

[១] ស្រីដែលជាគូនឹងព្រះពោធិសត្វ

[២] សាន ផល្លា ២០០៧: ១១៣ និង Danielle & Dominique-Pierre Guéret 2017: 74

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បើផ្អែកតាមផ្ទាំងចារឹកលើជញ្ជាំងព្រះវិហារវត្តភ្នំធនមន្តឱ្យដឹងថា ព្រះវិហារវត្តនេះ ចាប់ផ្តើមកឡើងតាំងពីឆ្នាំ១៩៤៧ រហូតហើយរួចរាល់ជាស្ថាពរក្នុងឆ្នាំ១៩៥៦។ ព្រះវិហារកសាងឡើងប្រកបដោយទឹកដៃសិល្បៈល្អឆើត ក្នុងទម្រង់ជាព្រះវិហារមណ្ឌប មានកំពូលមុខព្រហ្ម។ នៅជើងភ្នំផ្នែកខាងកើត មានជណ្តើរមួយកសាងតាំងពីឆ្នាំ១៩៥០ (រូបលេខ២-៣) ហើយនៅខាងជើងមានជណ្តើរ២ និងខាងលិចមានជណ្តើរ១ ភ្ជាប់មកទីធ្លាវត្តនៅជើងភ្នំផ្នែកខាងជើង ដែលមានសំណង់ផ្សេងៗដូចជា កុដិ សាលាឆាន់ សាលាបាលី ស្រះទឹក និងរោងទូកជាដើម។



រូបលេខ២-៣ ជណ្តើរឡើងព្រះវិហារវត្តភ្នំធនមន្តផ្នែកខាងកើត

នៅជើងភ្នំផ្នែកខាងជើង ស្ថិតនៅក្បែរជណ្តើរឡើង មានសាលាមួយខ្នងសង់ក្នុងឆ្នាំ១៩៥៦ គូរសាច់រឿងមយមាណព។ រីឯនៅលើកំពូលភ្នំមានសាលាបីទៀតសង់ព័ទ្ធព្រះវិហារផ្នែកខាងជើង ខាងត្បូង និងខាងលិច គូរសាច់រឿងផ្សេងៗគ្នាគួរឱ្យកត់សម្គាល់។ សាលាខាងជើងព្រះវិហារសង់ក្នុងឆ្នាំ១៩៥៧ គូរសាច់រឿងនិយាយអំពីនាងបដាចារតាំងពីដើមដល់ចប់។ សាលាខាងត្បូងកសាងពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៥៤ គូរសាច់រឿងមហាវេស្សន្តរជាតកទាំង១៣កណ្ឌ។ ចំណែកសាលាខាងលិចគេហៅថាសាលាប្រជុំបុណ្យមានគំនូរសាច់រឿងចម្រុះទាំងក្នុងពុទ្ធប្រវត្តិ និងរឿងនរកប្រេតនានា ហើយប្រហែលគូរក្នុងឆ្នាំ២០០៣។ ដោយឡែក នៅជ្រុងឦសានព្រះវិហារមានសំណង់មួយលំនាំហោត្រៃសង់ឡើងតម្កល់ព្រះធាតុព្រះចៅអធិការដំបូង។ ចំណែកឯនៅជាប់ខឿនព្រះវិហារផ្នែកខាងត្បូងមានសំណង់តូចមួយតម្កល់ព្រះពុទ្ធបដិមាចូលនិព្វាន និងរូបព្រះគោព្រះកែវជាទីដែលអ្នកមានជំនឿតែងចូលបួងសួងស្មើរាល់ថ្ងៃ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះវិហារមណ្ឌបកំពូលមុខព្រហ្មនៃវត្តភ្នំធនមន្ត ជាសំណង់នៅលើខឿនខ្ពស់មានខ្លោងទ្វារយ៉ាងវិចិត្រចំនួន៤ សង់ក្នុងរវាងទសវត្សទី៥០ ដែលនៅចំហៀងខាងជើងមាន២ និងខាងត្បូងមាន២។ ចំណែកឯតាមល្វែងបាំងសាច គេរចនាឱ្យមានជារូបបង្កាន់ដៃនាគព័ទ្ធជុំវិញ ដោយទុកជណ្តើរឡើងនៅផ្នែកខាងមុខនិងខាងក្រោយម្ខាង២។ នៅត្រង់ផ្នែក្រោមបង្កាន់ដៃជណ្តើរទាំងបួននោះ មានចម្លាក់ស្តើងៗឆ្លាក់អំពីស៊ីម៉ងត៍។ ម្ខាងឆ្លាក់រូបហនុមានកាន់ព្រះខ័ន ហើយម្ខាងទៀតជារូបដូចតួអង្គក្បត្រទ្រង់ធ្នូ ដេញសត្វចតុបាទមួយក្បាល ដែលប្រហែលដកស្រង់ពីរឿងរាមកេរ្តិ៍ (រូបលេខ២៤)។ រីឯនៅតាមស៊ុមទ្វារនីមួយៗ មានគូរជាក្បាច់លម្អ និងរូបព្រះពុទ្ធ ឬព្រះសិអារ្យមេត្រី (រូបលេខ២៥)។

សូមបញ្ជាក់ថានៅក្នុងឆ្នាំ២០០៣ ព្រះវិហារវត្តភ្នំធនមន្តបានជួសជុលលាបថ្នាំថ្មី។ ដូច្នេះគំនូរនិងក្បាច់ស៊ុមទ្វារនីមួយៗប្រហែលគូរក្នុងពេលនោះ។ បច្ចុប្បន្នព្រះវិហារនេះកំពុងជួសជុលបង្កាន់ដៃខឿនខាងក្រោម និងលាបថ្នាំម្តងទៀត ហើយគំនូរនិងក្បាច់ស៊ុមទ្វារទាំងអស់ត្រូវជំនួសដោយក្បាច់និងបដិមាចាក់ពុម្ពស៊ីម៉ងត៍វិញ។



រូបលេខ២៤-៥ ការលម្អនៅតាមជណ្តើររបៀងបាំងសាច និងនៅតាមស៊ុមទ្វារព្រះវិហារវត្តភ្នំធនមន្ត

ទោះបីយ៉ាងជាណាក្តី គេសម្គាល់ឃើញថាគ្រឿងគ្រោងដំបូលខាងលើនៃព្រះវិហារវត្តភ្នំធនមន្ត គឺប្រើជាប្រភេទបេតុងទាំងអស់។ ប៉ុន្តែដំបូលខាងលើ បិទលម្អបន្ថែមដោយការ៉ូចម្រុះពណ៌ ពោលគឺពុំប្រើក្បឿងឡើយ ហើយតាមចុងព្រំដំបូលមុខ-ក្រោយ បំពាក់លម្អដោយជហ្វាម្ខាង៣ ឯនៅតាមចុងព្រំដំបូលខាងជើង និងខាងត្បូងបំពាក់លម្អដោយជហ្វាម្ខាង២។ ដោយឡែកលើហោជាងទាំងបួនទិសនៃព្រះវិហារនេះ គេឃើញលម្អដោយក្បាច់និងរូបពីរប្រភេទ។ ហោជាងខាងកើតនិងខាងលិចលម្អដោយរូបសិង្ហ(?)លើកជើង

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មុខទល់គ្នានៅមុខថូផ្កាមួយ ហើយទ្រដោយក្បាច់ភ្ញីទេសនៅផ្នែកខាងក្រោម (រូបលេខ២៦)។ ហោជាងខាងជើងនិងខាងត្បូងលម្អដោយហង្សមួយគូឈរទល់មុខគ្នា ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេស។ ប៉ុន្តែនៅគល់ហោជាងខាងជើងនិងខាងត្បូងនេះ គេគូរទេសភាពផ្សេងៗលម្អបន្ថែមទៀត (រូបលេខ២៧)។



រូបលេខ២៦-៧ ការលម្អទាំងពីរបែបនៅលើហោជាងព្រះវិហារវត្តភ្នំធនមន្ត

ចំពោះផ្នែកខាងក្នុងព្រះវិហារ គេចែកជាបីល្វែងដូចព្រះវិហារទូទៅដែរ ពោលគឺមានល្វែងគ្រឹះនៅកណ្ដាល អមដោយរបៀងសងខាង ដែលបង្កើតបានជាបីល្វែងយ៉ាងធំទូលាយសម្រាប់រៀបចំធ្វើកិច្ចពិធីផ្សេងៗតាមទំនៀម។ ស្ថិតនៅអមល្វែងគ្រឹះនេះដែរ មានសសរបេតុងមូលធំៗពីរជួរទ្រពិតាន ដែលសសរនីមួយៗសុទ្ធតែគូរលម្អដោយរូបនាគរុំកន្ទុយចុះមកពីលើយ៉ាងអង់អាចក្រៃលែង។

នៅត្រង់ខាងចុងល្វែងគ្រឹះផ្នែកខាងលិច គឺជាបល័ង្កព្រះជីរ៍ ដែលតម្កល់ខ្ពស់ក្នុងកាយវិហារផ្ចាញ់មារ។ បើផ្អែកតាមចារឹកមួយផ្ទាំងខាងក្រោយព្រះប្រឹស្ឋ ព្រះពុទ្ធបដិមាព្រះជីរ៍អង្គនេះសាងឡើងក្នុងពុទ្ធសករាជ២៤៩៨ (គ.ស.១៩៥៥) ហើយធ្វើបុណ្យភិសេកក្នុងពុទ្ធសករាជ២៥០២ (គ.ស.១៩៥៩) ដោយថ្វាយព្រះនាមថា "ព្រះវិរិយមេតេយ្យោពុទ្ធោ" ដែលគេទុកដូចជាតំណាងព្រះសិអារ្យមេត្រី។ ការថ្វាយព្រះនាមដល់ព្រះបដិមាព្រះជីរ៍ក្នុងព្រះវិហារបែបនេះជាការកម្រប្រទះឃើញណាស់ ហើយព្រះជីរ៍អង្គនេះសោតក៏ជាព្រះជីរ៍ដែលបានរួចពីការបំផ្លាញក្នុងសម័យសង្គ្រាម បើធៀបនឹងព្រះជីរ៍តាមបណ្ដាព្រះវិហារបុរាណផ្សេងទៀត (រូបលេខ២៨)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៨ ព្រះពុទ្ធបដិមាព្រះជីវ័វត្តភ្នំធនមន្តព្រះនាម "ព្រះរិរិយមេតេយ្យោពុទ្ធោ"

ដោយឡែកចំពោះគំនូរខាងក្នុងព្រះវិហារវត្តភ្នំធនមន្ត គេដឹងថាគូរក្នុងឆ្នាំ១៩៥៨ ដោយព្រះសង្ឃព្រះនាម អាក់ ឥន្ទ។ ផ្ទាំងគំនូរតូចធំទាំងអស់មានចំនួនជាង៥០ផ្ទាំងដែលគូរនៅលើផ្ទៃជញ្ជាំងជុំវិញ និងលើពិតាន។ ប៉ុន្តែប្រធានបទជាធំលើកយកមកគូរ គឺរឿងផ្សេងៗពាក់ព័ន្ធនឹងជាតិកំណើតនាងពិម្ពាកាលពីអតីតជាតិ ដែលគេដឹងថាមាននិយាយក្នុងគម្ពីរសន្ធរាននិព្វាន។ ក្នុងឆ្នាំ១៩៦០ អ្នកឧកញ៉ាវិបុលរាជសេនា នូ កន បានចម្លងរឿងផ្សេងៗនៃគម្ពីរនេះចេញពីសាស្ត្រាស្លឹករឹតបោះពុម្ពដាក់ចំណងជើងថា "ពិម្ពានិព្វាន" ដោយបែងចែកជាភាគ។[៣] តាមរយៈសាច់រឿងក្នុងគម្ពីរនេះ គេដឹងថាជារឿងដែលមានឥទ្ធិពលពីរឿងក្នុងជាតកផ្សេងៗដូចជា បញ្ញាសជាតក និងធម្មបទដ្ឋកថាជាដើម។[៤]

[៣] នូ កន ១៩៦០

[៤] សាន ផល្លា ២០០៧: ១១៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ ព្រះវិហារវត្តភ្នំធនមន្តនិងគំនូររឿងនាងពិម្ពា

សាច់រឿងក្នុងព្រះវិហារនេះ ចាប់ផ្តើមគូរពីជ្រុងខាងកើតនៃជញ្ជាំងខាងត្បូង ដោយសាច់រឿងជាទូទៅលើកមកគូរខ្លះនិយាយអំពីព្រះពុទ្ធអង្គនិងនាងពិម្ពាយកកំណើតជាប្តីប្រពន្ធកំសត់ទុរគត់ តែមានសទ្ធាជ្រះថ្លាចំពោះព្រះអរហន្ត រឿងខ្លះនិយាយអំពីនាងពិម្ពានិងព្រះពុទ្ធអង្គយកកំណើតជាបក្សី ឬជាត្រី ឬជាស្តេច ឥសី តាបស ឬព្រាហ្មណ៍ជាដើម។ ជាក់ស្តែងដូចជាសាច់រឿងក្នុងរូបលេខ៩ និយាយពីជាតិដែលព្រះអង្គកើតជា "អតិទុក្កមាណព" យកករិយាទៅលក់យកប្រាក់សង់កុដិថ្វាយព្រះអរហន្ត។ លុះរំលាងសង្ខារទៅបានកើតក្នុងស្ថានសួគ៌ទេវលោក។ ឯរឿងក្នុងរូបលេខ១០ និយាយពីជាតិដែលព្រះអង្គកើតជាត្រីរាជ ឯនាងពិម្ពាកើតជាបក្សីហើយជ្រះថ្លាដាក់ទានជីវិតឱ្យក្អែចចក។





រូបលេខ៩ កាលព្រះអង្គកើតជាមាណពកំសត់ រូបលេខ១០ កាលព្រះអង្គកើតជាត្រីរាជ

គំនូររឿងដែលពាក់ព័ន្ធនឹងជាតិកំណើតផ្សេងៗរបស់នាងពិម្ពា និងព្រះពុទ្ធអង្គក្នុងអតីតជាតិនោះ រៀបរាប់ហូរហែតាមជញ្ជាំងនិងពិតានរហូតដល់ផ្ទាំងទី៤២។ ផុតអំពីនោះមក វិចិត្រករគូរបញ្ចូលសាច់រឿងត្រង់ពិធីអភិសេកព្រះវេស្សន្តរ និងនាងមេទ្រី១ផ្ទាំង និងបន្តមករឿងពុទ្ធប្រវត្តិត្រង់ព្រះអង្គចេញបួស ទុក្ករកិរិយា ត្រាស់ដឹង (គូររួមគ្នា១ផ្ទាំង) ទ្រង់

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*ប្រឈួន រហូតបរិនិព្វាន (រូបលេខ១១) និងព្រះឥន្ទនាំយកព្រះចង្កូមកែវទៅឋានត្រៃត្រិង្ស ជាចុងបញ្ចប់នៅត្រង់លើពិតានមុខព្រះជីវ៍ ក្បែរផ្ទាំងរូបព្រះអាទិត្យ និងព្រះចន្ទ្រ។*



*រូបលេខ១១ គំនូរព្រះចូលនិព្វានគូរលើពិតានព្រះវិហារវត្តភ្នំធនមន្ត*

*សង្ខេបសេចក្តីមក ព្រះវិហារវត្តភ្នំធនមន្ត គឺជាស្ថាបត្យកម្មព្រះពុទ្ធសាសនាល្អប្លែកមួយគួរឱ្យសិក្សាស្រាវជ្រាវលម្អិតវែងឆ្ងាយតទៅមុខ ពោលគឺទាំងប្លង់ស្ថាបត្យកម្ម និងការលើកយកសាច់រឿងផ្សេងៗមកគូរបង្ហាញទាំងក្នុងព្រះវិហារ និងតាមសាលាជុំវិញ។ ទន្ទឹមនេះព្រះវិហារវត្តភ្នំធនមន្តក៏ជាសំណង់ដែលបង្ហាញឱ្យឃើញច្បាស់ពីទឹកដៃ និងចំណេះផ្នែកសំណង់សាសនារបស់អ្នកស្រុកផងដែរ។*

អរិយធម៌ខ្មែរ
KHMER CIVILIZATION

## ឯកសារយោង

*នូ កន*

*១០៦០, ពិម្ពានិព្វាន, ភាគ១, បណ្ណាគារ គិម សេង, ភ្នំពេញ*

*សាន ផល្លា*

*២០០៧, គំនូរនៅតាមវត្ត, រៃឃំ, ភ្នំពេញ*

Danielle & Dominique-Pierre Guéret,

2017, *The Khmer Pagoda,* Kam Edition

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*